# កិច្ចការពារប្រឆាំងការសងសឹក នៅក្រោមច្បាប់ ស្តីពីប្រាក់ឈ្នួល និង ម៉ោងធ្វើការ នៃរដ្ឋម៉ាសាឈូសេត

## តើមានការការពារអ្វីខ្លះ សម្រាប់និយោជិត ដែលប្រើប្រាស់សិទ្ធិរបស់ខ្លួន នៅក្រោមច្បាប់ស្តីពីប្រាក់ឈ្នួល និង ម៉ោងធ្វើការ នៃរដ្ឋម៉ាសាឈូសេត?

ច្បាប់រដ្ឋម៉ាសាឈូសេត ហាមឃាត់និយោជក មិនឲ្យចាត់<u>វិធានការណាមួយប្រឆាំង</u>និយោជិត ដោយសារតែនិយោជិតនោះបាន៖

- ដាក់បណ្តឹងនៅការិយាល័យអគ្គរដ្ឋអាជ្ញា។
- ប្តឹងទៅនរណាម្នាក់ អំពីសិទ្ធិរបស់គាត់ (ឬ ប្តឹងទៅអ្នកធ្វើការជាមួយគ្នា) នៅក្រោមច្បាប់ស្តីពីប្រាក់ឈ្នួល និង ម៉ោងធ្វើការ របស់រដ្ឋម៉ាសាឈូសេត។
- ចូលរួម ឬ ជួយក្នុងការស៊ើបអង្កេត ឬ កិច្ចដំណើរការនីតិវិធី ពាក់ព័ន្ធនឹងការចោទប្រកាន់ អំពីការរំលោភបំពានលើច្បាប់ស្តីពីប្រាក់ឈ្នួល និង ម៉ោងធ្វើការ។
- ចាត់វិធានការណាមួយ ដើម្បីចាប់ផ្តើមកិច្ចដំណើរការនីតិវិធី ពាក់ព័ន្ធនឹងការចោទប្រកាន់ អំពីការរំលោភបំពានលើច្បាប់ស្តីពីប្រាក់ឈ្នួល និង ម៉ោងធ្វើការ ឬ
- ធ្វើសក្ខីកម្ម ឬ គ្រោងធ្វើសក្ខីកម្ម នៅក្នុងកិច្ចដំណើរការនីតិវិធីបែបនេះ។

## តើអ្វីខ្លះជាឧទាហរណ៍នៃ "ចំណាត់ការសងសឹក" ខុសច្បាប់?

ច្បាប់របស់រដ្ឋម៉ាសាឈូសេត ហាមឃាត់និយោជក មិនឲ្យដាក់ពិន័យ ឬ ធ្វើបាបនិយោជិតណាម្នាក់ ទោះតាមមធ្យោបាយណារួមទាំង <u>ការគម្រាមកំហែង</u> ថានឹងដាក់ពិន័យ ឬ ធ្វើបាបនិយោជិតណាម្នាក់ <u>ដោយសារ</u> និយោជិតនោះបានប្រើប្រាស់សិទ្ធិគាត់ដូចមានចែងក្នុងច្បាប់ស្តីពីប្រាក់ឈ្នួល និង ម៉ោងធ្វើការ។ ឧទាហរណ៍ នៃចំណាត់ការសងសឹកលើបុគ្គលិក រួមមាន

- ការបញ្ឈប់និយោជិតពីការងារ ឬ ការបណ្តេញនិយោជិតចេញពីការងារ។
- ការរើសអើងលើនិយោជិតណាម្នាក់ តាមរូបភាពណាមួយ ឧទាហរណ៍ ដកម៉ោងធ្វើការ ឲ្យការងារពិបាកទៅនិយោជិតធ្វើ ឬ ផ្លាស់ប្តូរពេលម៉ោងធ្វើការ។
- វាយប្រហារនិយោជិត។
- ដាក់និយោជិតក្នុងបញ្ជីខ្មៅ ឬ បរិហារបង្ខូចកេរ្តិ៍និយោជិត រួមទាំងការការចេញលិខិតបង្គាប់និយោជិត ដែលប៉ះពាល់ដល់ការរកការងារធ្វើ ទៅថ្ងៃអនាគត។
- ធ្វើរបាយការណ៍ក្លែងក្លាយ អំពីបទល្មើសឧក្រិដ្ឋ វាយការណ៍ទៅអាជ្ញាធរអំពីនិយោជិត ឬ
- វាយការណ៍ទៅសមត្ថកិច្ចខាងអន្តោប្រវេសន៍ អំពីនិយោជិត ឬ
- គម្រាមកំហែងនិយោជិត ឬ ក្រុមគ្រួសារគាត់ អំពីចំណាត់ការសងសឹកណាមួយ និង ព្រមានអំពីផលវិបាក ឬគ្រោះថ្នាក់ ពីការប្រើសិទ្ធិនេះ។

## តើអ្វីខ្លះជាទោសទណ្ឌរដ្ឋប្បវេណី និង/ឬ ព្រហ្មទណ្ឌ ដែលនិយោជកអាចប្រឈម ដោយសារតែបំពានបទប្បញ្ញត្តិទាំងនេះ?

- ពិន័យផ្នែករដ្ឋប្បវេណី រហូតដល់ ១៥,000 ដុល្លារ ក្នុងករណីបំពានមួយករណី
- សងប្រាក់ឈ្នួលចន្លោះពីមួយខែ ដល់ពីរខែ ឬ
- ពិន័យជាប្រាក់ មិនលើសពី ២៥,000 ដុល្លារ ឬ ដាក់ពន្ធនាគារមិនឲ្យលើសពីមួយឆ្នាំ ចំពោះបទល្មើសដំបូង។

ច្បាប់ស្តីពីការប្រឆាំងនឹងការសងសឹក ពាក់ព័ន្ធនឹងច្បាប់ស្តីពីប្រាក់ឈ្នួល និង ម៉ោងធ្វើការ មានក្នុងឯកសារ M.G.L. c. 149 ផ្នែក 148A និង M.G.L. c. 151, ផ្នែក 19 (1) និង (5)។

**ដើម្បីជ្រាប់ព័ត៌មានបន្ថែម ពាក់ព័ន្ធនឹងច្បាប់ស្តីពីប្រាក់ឈ្នួល និង ម៉ោងធ្វើការ ឬ ដើម្បីទទួលបានទម្រង់ពាក្យបណ្តឹង សូមចូលមើលគេហទំព័រ៖ www.mass.gov/ago/fairlabor ឬទូរស័ព្ទ៖ (617)727-3465**

OFFICE OF ATTORNEY GENERAL MAURA HEALEY
FAIR LABOR DIVISION
ONE ASHBURTON PLACE • BOSTON, MA 02108
PHONE: (617) 727-2200 • TTY: (617) 727-4765
WWW.MASS.GOV/AGO/FAIRLABOR